# សុន្ទរកថា
# អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី,
# រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
# ថ្លែងក្នុង
# ពិធីប្រកាសសុពលភាព និង ការចូលកាន់តំណែងរបស់
# ក្រុមប្រឹក្សាភិបាល និង នាយកប្រតិបត្តិនៃពហុកីឡដ្ឋានជាតិ

រាជធានីភ្នំពេញ, ថ្ងៃពុធ ៥ រោច ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨

ត្រូវនឹងថ្ងៃទី ២៦ ខែ មិថុនា គ.ស. ២០២៤, វេលាម៉ោង ៩ ព្រឹក, កីឡដ្ឋានមរតតេជោ

*****+*****

- ឯកឧត្តមបណ្ឌិត **ថោង ខុន**, ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និង ជាប្រធានគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា;
- ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី!

ថ្ងៃនេះ, ខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយ ដោយបានមកចូលរួមជាអធិបតីក្នុងពិធីប្រកាសសុពលភាព និង ការចូលកាន់តំណែង របស់ក្រុមប្រឹក្សាភិបាល និង នាយកប្រតិបត្តិ នៃពហុកីឡដ្ឋានជាតិ ដែលទើបត្រូវបានតែងតាំងជាផ្លូវការ នាពេលថ្មីៗកន្លងទៅ ។

ជាមួយគ្នានេះ, ខ្ញុំពិតជាមានមោទនភាពខ្ពស់ ដោយបានកត់សម្គាល់ឃើញថា វិស័យកីឡានៅកម្ពុជា បាន និង កំពុងបន្តបោះជំហានទៅរកការរីកចម្រើន ក្នុងកម្រិតថ្មីមួយទៀត តាមរយៈចំនួនមេដាយដែលអត្តពលិកកម្ពុជាទទួលបាន ក្នុងព្រឹត្តិការណ៍នៃការ-ប្រកួតកីឡាអាស៊ីអាគ្នេយ៍ លើកទី ៣២ និង អាស៊ានប៉ារ៉ាហ្គេម លើកទី ១២ ដែលកម្ពុជាបានធ្វើជាម្ចាស់ផ្ទះ កាលពីឆ្នាំ ២០២៣ ប្រកបដោយជោគជ័យដ៏ត្រចះត្រចង់ ជាប្រវត្តិសាស្ត្រ ។ ជោគជ័យដ៏ធំធេងរបស់យើង ក្នុងការរៀបចំព្រឹត្តិការណ៍នៃការប្រកួតកីឡាអាស៊ីអាគ្នេយ៍ លើកទី ៣២ និង អាស៊ានប៉ារ៉ាហ្គេម លើកទី ១២ បានធ្វើឲ្យបណ្តាប្រទេស, ទាំងក្នុងតំបន់

និង លើសកលលោក, ភ្ញាក់ផ្អើល និង សម្តែងនូវការសារទរ និង ការកោតសរសើរ ចំពោះរាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ឈ្លាសវៃ ប្រកបដោយគតិបណ្ឌិត និង ចក្ខុវិស័យវែងឆ្ងាយ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**, **ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា,** ក្នុងឋានៈសម្តេច ជានាយករដ្ឋមន្ត្រី នាពេលនោះ ។ ពិតណាស់ថា ជោគជ័យដ៏ធំធេងនេះ មិនមែនកើតឡើងដោយចៃដន្យនោះទេ, ពោលគឺ កើតចេញពីចលនាសាមគ្គីភាពរឹងមាំ ពីសំណាក់យុវជន និង ប្រជាជនគ្រប់ស្រទាប់វណ្ណៈ នៅទូទាំងប្រទេស, កិច្ចសហការស្អិតល្មួត រវាងក្រសួង-ស្ថាប័នពាក់ព័ន្ធ, ជាពិសេស ការរៀបចំចាត់ចែងបានល្អ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ពីសំណាក់គណៈកម្មាធិការជាតិរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍ លើកទី ៣២, ក្រោមការដឹកនាំរបស់ **សម្តេចពិជ័យសេនា ទៀ បាញ់**, គួបផ្សំនឹងការជួយជ្រោមជ្រែងពេញទំហឹង ពីសំណាក់មិត្តចិន តាមរយៈការផ្តល់នូវហិរញ្ញប្បទានឥតសំណងដ៏សន្ធឹកសន្ធាប់ សម្រាប់សាងសង់ **ពហុកីឡដ្ឋានជាតិមរតកតេជោ** និង ការ-ចាត់បញ្ជូន នូវអ្នកជំនាញបច្ចេកទេស ដើម្បីចូលរួមរៀបចំពិធីបើក និង ពិធីបិទនៃព្រឹត្តិ-ការណ៍ជាប្រវត្តិសាស្ត្រទាំងពីរ ។

**ពហុកីឡដ្ឋានជាតិមរតកតេជោ** ត្រូវបានចាត់ទុកជាសមិទ្ធផលដ៏ធំស្កឹមស្កៃ និង ជាសំណង់ប្រវត្តិសាស្ត្រមួយរបស់កម្ពុជា ក្នុងយុគសម័យទំនើប ។ ក្នុងន័យនេះ, យើងទាំង-អស់គ្នា ត្រូវចូលរួមខិតខំថែរក្សាមរតកជាតិនេះ ឲ្យបានល្អ និង គង់វង្សយូរអង្វែង ព្រមទាំងគប្បីប្រើប្រាស់ពហុកីឡដ្ឋាននេះ និង ពហុកីឡដ្ឋានជាតិអូឡាំពិក, ឲ្យមានប្រសិទ្ធភាពខ្ពស់ ដើម្បីកៀរគរចំណូល ឲ្យបានជាអតិបរមា សំដៅកាត់បន្ថយបន្ទុកចំណាយថវិការដ្ឋ ស្របតាមអភិក្រម **«ពហុកីឡដ្ឋានជាតិ ចិញ្ចឹមពហុកីឡដ្ឋានជាតិ»** ។ នេះ គឺជាមូលហេតុចម្បង ដែលរាជរដ្ឋាភិបាលបានសម្រេចបង្កើតពហុកីឡដ្ឋានជាតិ ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ។

តាមរយៈរបាយការណ៍របស់ ឯកឧត្តម **វ៉ាត់ ចំរើន**, រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និង កីឡា, និង ជាអគ្គលេខាធិការនៃគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា, ខ្ញុំសូមសម្តែងនូវការកោតសរសើរ និង ការវាយតម្លៃខ្ពស់ ចំពោះថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និង កីឡា, គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា, គណៈកម្មាធិការជាតិរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍ លើកទី ៣២ (CAMSOC), សហព័ន្ធកីឡាជាតិ, និង តួអង្គពាក់ព័ន្ធផ្សេងទៀត ដែលបានសហការជិតស្និទ្ធ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ក្នុងការប្រើប្រាស់ និង ការថែទាំហេដ្ឋារចនាសម្ព័ន្ធនៃ **ពហុកីឡដ្ឋានជាតិមរតកតេជោ** និង **ពហុកីឡដ្ឋានជាតិអូឡាំពិក** ក្នុងស្មារតីស្រឡាញ់ទ្រព្យសម្បត្តិសាធារណៈរបស់ជាតិ ។

***ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី!***

ជាមួយនឹងការបន្តគិតគូរដ៏ខ្ពង់ខ្ពស់ ប្រកបដោយចក្ខុវិស័យវែងឆ្ងាយ របស់ **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**, **នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា,** រាជរដ្ឋាភិបាល, នីតិកាលទី ៧ នៃរដ្ឋសភា, បានសម្រេចបង្កើតពហុកីឡដ្ឋានជាតិ ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល តាមរយៈអនុក្រឹត្យ លេខ ៣៩ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០២៤ ដែលមានក្រសួងអប់រំ យុវជន និង កីឡា, ជាអាណាព្យាបាលបច្ចេកទេស, និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, ជាអាណាព្យាបាលហិរញ្ញវត្ថុ, ក្នុងគោលបំណងគ្រប់គ្រង, ថែទាំ, ជួសជុល, និង ប្រើប្រាស់ ពហុកីឡដ្ឋានជាតិ, ដែលជាទ្រព្យសម្បត្តិដ៏សម្បើមរបស់រដ្ឋ, ឲ្យបានគង់វង្សយូរអង្វែង ដើម្បីទុកជាមរតកដ៏ថ្លៃថ្លា សម្រាប់ជាតិ និង ប្រជាជនកម្ពុជា ជំនាន់ក្រោយទៀត ។ លើសពីនេះ, ការបង្កើតគ្រឹះស្ថានពហុកីឡដ្ឋានជាតិឡើង ក៏នឹងផ្ដល់លទ្ធភាព ឲ្យអង្គភាពរដ្ឋមួយនេះ អាចមានស្វ័យភាពថវិកា និង អាចធ្វើសកម្មភាពកៀរគរចំណូល ឲ្យអស់សក្ដានុពល ពីការប្រើប្រាស់ពហុកីឡដ្ឋានជាតិ សំដៅកាត់បន្ថយបន្ទុកចំណាយថវិការដ្ឋជាបណ្ដើរៗ និង អាចក្រសោបយកកាលានុវត្តភាពនៃការពង្រីកប្រភពចំណូលពាក់ព័ន្ធផ្សេងៗ ដើម្បីធានានិរន្តរភាពនៃថវិកា សម្រាប់ទ្រទ្រង់ដល់កិច្ចដំណើរការនៃការពង្រីកហេដ្ឋារចនាសម្ព័ន្ធគាំទ្រចាំបាច់មួយចំនួន ក៏ដូចជា សម្រាប់អភិវឌ្ឍវិស័យកីឡានៅកម្ពុជា ឲ្យកាន់តែមានការរីកចម្រើនឈានឡើងជាលំដាប់ បន្ថែមទៀត ។

បន្ថែមលើការប្ដេជ្ញាចិត្តរបស់ ឯកឧត្តមបណ្ឌិត **ឈន សុភាព** ប្រធានក្រុមប្រឹក្សាភិបាល និង ឯកឧត្តម **សេង តុលា** នាយកប្រតិបត្តិ នៃពហុកីឡដ្ឋានជាតិ, ខ្ញុំសូមផ្ដល់អនុសាសន៍សំខាន់មួយចំនួន ដូចខាងក្រោម៖

**ទី១.** ក្រុមប្រឹក្សាភិបាលនៃពហុកីឡដ្ឋានជាតិ, ដែលត្រូវបានតែងតាំងជាផ្លូវការរួចហើយ, ត្រូវរៀបចំកិច្ចប្រជុំ លើកទី ១ របស់ខ្លួន ឲ្យបានឆាប់តាមការណ៍អាចធ្វើទៅបាន ដើម្បីពិនិត្យ, ពិភាក្សា, និង អនុម័ត លើសេចក្ដីព្រាងឯកសារអាទិភាពមួយចំនួន មានជាអាទិ៍៖ អនុក្រឹត្យ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃពហុកីឡដ្ឋានជាតិ, ប្រកាសអន្តរក្រសួង ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃពហុកីឡដ្ឋានជាតិ, គម្រោងថវិកាឆ្នាំ ២០២៤ និង ២០២៥, ការស្នើសុំកំណត់ប្រាក់ឧបត្ថម្ភ សម្រាប់ថ្នាក់ដឹកនាំ និង មន្ត្រី-បុគ្គលិក ព្រមទាំងការជ្រើសរើសមន្ត្រី-បុគ្គលិក សម្រាប់បម្រើការងារនៅពហុកីឡដ្ឋានជាតិ ។

**ទី២.** ក្នុងអន្តរកាលនៃការគ្រប់គ្រងពហុកីឡដ្ឋានជាតិមរតកតេជោ, ខ្ញុំសូមស្នើឱ្យគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា ដែលមាននាយកដ្ឋានគ្រប់គ្រងពហុកីឡដ្ឋានជាតិមរតកតេជោ ជាសេនាធិការ, ផ្តល់កិច្ចសហការល្អ និង ជិតស្និទ្ធជាមួយគណៈគ្រប់គ្រងពហុកីឡដ្ឋានជាតិ ក្នុងការប្រគល់-ទទួលឯកសារ និង ការផ្ទេរការងារពាក់ព័ន្ធនឹងពហុកីឡដ្ឋានជាតិមរតកតេជោ ជាបណ្តើរៗ ដោយត្រូវបញ្ចប់នៅមុនដំណាច់ឆ្នាំ ២០២៤ នេះ ។

**ទី៣.** ក្នុងរយៈពេលពីរឆ្នាំខាងមុខ, ខ្ញុំស្នើឲ្យមានការគិតគូរជាបណ្តើរៗ លើការដាក់បញ្ចូលពហុកីឡដ្ឋានជាតិអូឡាំពិក និង កីឡដ្ឋានផ្សេងទៀត ស្ថិតនៅក្រោមការគ្រប់គ្រងរបស់គ្រឹះស្ថានពហុកីឡដ្ឋានជាតិ ស្របតាមខ្លឹមសារនៃអនុក្រឹត្យ លេខ ៣៩ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០២៤ ។ ក្នុងទិសដៅនេះ, ខ្ញុំសូមស្នើក្រសួងអប់រំ យុវជន និង កីឡា បង្កើតក្រុមការងារចំពោះកិច្ចមួយ ដោយមានសមាសភាពពីតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីពិនិត្យ និង វាយតម្លៃស្ថានភាពនៃពហុកីឡដ្ឋានជាតិអូឡាំពិក និង ធ្វើរបាយការណ៍គោរពជូន **សម្តេចធិបតី នាយករដ្ឋមន្ត្រី** ជ្រាប, ពិនិត្យសម្រេច និង ផ្តល់ការណែនាំដ៏ខ្ពង់ខ្ពស់ ជាយថាហេតុ ។

**ទី៤.** ក្នុងខណៈដែលថវិកាសម្រាប់ដំណើរការពហុកីឡដ្ឋានជាតិនេះ ក្នុងឆ្នាំ ២០២៤ មិនទាន់ត្រូវបានគ្រោងនៅឡើយ, ដើម្បីដោះស្រាយតម្រូវការចំណាយចំពោះមុខរហូតដល់ដំណាច់ឆ្នាំ, ខ្ញុំស្នើឲ្យអគ្គនាយកដ្ឋានថវិកា និង អគ្គនាយកដ្ឋានរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សហការជាមួយក្រសួងអប់រំ យុវជន និង កីឡា ដែលជាអាណាប័កដើមខ្សែ ពិនិត្យលទ្ធភាពផ្តល់ថវិកា ជូនដល់ពហុកីឡដ្ឋានជាតិតាមយន្តការបុរេប្រទាន ដូចធ្លាប់បានអនុវត្តជាមួយមន្ទីរពេទ្យលួងម៉ែ និង មន្ទីរពេទ្យតេជោសន្តិភាព ។ ដោយឡែក, ចាប់ពីឆ្នាំ ២០២៥ ទៅ, ពហុកីឡដ្ឋានជាតិ ត្រូវអនុវត្តថវិកា តាមយន្តការជាគ្រឹះស្ថានសាធារណៈរដ្ឋបាលពេញលេញ ។

**ទី៥.** ខ្ញុំសូមស្នើឲ្យគណៈគ្រប់គ្រងពហុកីឡដ្ឋានជាតិ ពិនិត្យ និង សិក្សាលម្អិតអំពីលទ្ធភាពនៃការវិនិយោគបន្ថែម លើការសាងសង់ហេដ្ឋារចនាសម្ព័ន្ធគាំទ្រចាំបាច់មួយចំនួនក្នុងទីតាំងដែលមានស្រាប់ និង ការបង្កើតសេវាថ្មី សម្រាប់រកចំណូលបន្ថែម ដើម្បីមានលទ្ធភាពចិញ្ចឹមពហុកីឡដ្ឋាជាតិ ប្រកបដោយនិរន្តរភាព និង ដើម្បីអាចប្រើប្រាស់សម្រាប់ការទទួលរៀបចំព្រឹត្តិការណ៍ធំៗ, ទាំងកម្រិតជាតិ និង អន្តរជាតិ ។

**ទី៦.** ដោយពហុកីឡដ្ឋានជាតិមរតកតេជោ មានទីតាំងឆ្ងាយពីទីប្រជុំជន, ខ្ញុំសូមស្នើឲ្យគណៈគ្រប់គ្រងពហុកីឡដ្ឋានជាតិ យកចិត្តទុកដាក់បន្ថែម លើគុណភាពសេវា, បរិស្ថាន, អនាម័យ, សុវត្ថិភាព, និង សន្តិសុខ នៅក្នុងបរិវេណ និង នៅជុំវិញពហុកីឡដ្ឋានជាតិ ដើម្បីបង្កើនភាពទាក់ទាញ ឲ្យប្រជាពលរដ្ឋ, ទាំងអ្នករស់នៅជិតតំបន់នេះ និង អ្នកនៅឆ្ងាយ, អាចមកលេងកំសាន្ត ដោយក្តីរីករាយ និង បង្កើតការចងចាំល្អៗ ។ និង

**ទី៧.** ខ្ញុំសូមអំពាវនាវក្រសួង-ស្ថាប័នសាធារណៈ និង វិស័យឯកជន ផ្តល់ការគាំទ្រដល់ពហុកីឡដ្ឋានជាតិ តាមរយៈការប្រើប្រាស់សេវា និង ការជួលទីតាំង សម្រាប់រៀបចំកម្មវិធីផ្សេងៗ ដែលទាក់ទងនឹងកីឡា, វប្បធម៌, សិល្បៈ, ការកំសាន្ត, និង ការតាំងពិពណ៌ ។ល។

## *ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី!*

មុននឹងបញ្ចប់, ខ្ញុំសូមវាយតម្លៃខ្ពស់ ចំពោះថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និង កីឡា, ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ, ក្រសួងទេសចរណ៍, គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា, និង រដ្ឋបាលរាជធានីភ្នំពេញ ដែលបានចាត់តំណាង ចូលរួមជាអនុប្រធាន និង ជាសមាជិកក្រុមប្រឹក្សាភិបាលនៃពហុកីឡដ្ឋានជាតិ ស្របតាមស្មារតីនៃអនុក្រឹត្យ លេខ ៣៩ អនក្រ.បក. ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០២៤ ស្តីពីការបង្កើតពហុកីឡដ្ឋានជាតិ ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ។

ខ្ញុំសូមលើកទឹកចិត្តឲ្យក្រុមប្រឹក្សាភិបាល និង នាយកប្រតិបត្តិនៃពហុកីឡដ្ឋានជាតិ ដែលត្រូវបានប្រកាសសុពលភាព នាថ្ងៃនេះ ខិតខំបំពេញតួនាទី និង ភារកិច្ចរបស់ខ្លួន ប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ, តម្លាភាព, គណនេយ្យ, និង ស្មារតីទទួលខុសត្រូវខ្ពស់ ចំពោះអាណាព្យាបាលបច្ចេកទេស និង អាណាព្យាបាលហិរញ្ញវត្ថុ ស្របតាមច្បាប់ និង លិខិតបទដ្ឋានគតិយុត្តជាធរមាន ។

ជាទីបញ្ចប់, ជាមួយនឹងការប្រកាសសុពលភាព និង ការចូលកាន់តំណែង របស់ក្រុមប្រឹក្សាភិបាល និង នាយកប្រតិបត្តិ នៃពហុកីឡដ្ឋានជាតិ, ខ្ញុំសូមជូនពរ ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី, បានប្រកបដោយសុខភាពល្អបរិបូរណ៍, កម្លាំងមាំមួន, មានសុភមង្គលក្នុងក្រុមគ្រួសាររៀងៗខ្លួន និង សម្រេចបានជោគជ័យដ៏ត្រចះត្រចង់ ក្នុងគ្រប់ភារកិច្ច នៅក្រោមម្លប់ដ៏ត្រជាក់នៃសុខសន្តិភាពដែល **សម្តេចតេជោ ហ៊ុន សែន** បាននាំមកជូនជាតិ និង ប្រជាជនកម្ពុជា ៕

*សូមអរគុណ !*